# រឿង គ្រប់ក្តីស្រលាញ់ទាំងអស់គឺស្រស់ស្អាត

## *All Love is beautiful*



ឡុង ពិសី
ស៊ិន ធួកណា

# គ្រប់ក្ដីស្រលាញ់ទាំងអស់គឺស្រស់ស្អាត (ALL LOVE IS BEAUTIFUL)

**Written by** Long Pisey
**Artwork by** Sin Thuokna

**Co-Editors** Sai Yee Tip,
Prak Monirath,
Uoeung Bonsovathary

**Art Editor** San Somanear

**Reviewed by** Khmer Youth Association (KYA),
Love is Diversity

Publisher Khmer Youth Association (KYA)
No. 32D, St. 562, Phnom Penh12151, Cambodia

Copyright © 2024 by Khmer Youth Association (KYA)

All rights reserved.
Without limiting the rights under the copyright reserved above, no part of this publication may be reproduced, stored in or introduced into a retrieval system, or transmitted, in any form, or by any means (electronic, mechanical, photocopying, recording, or otherwise), without the prior written permission of the copyright owner.
Published in Phnom Penh, Cambodia.

A catalog record for this book is available from
the National Library of Cambodia
ISBN: 978-9924-9966-4-4

Disclaimer: This storybook is made possible by the generous support of the American people through the United States Agency for International Development (USAID)-funded Civil Society Support (CSS) Activity implemented by Family Health International (FHI360). The contents are the responsibility of Khmer Youth Association and do not necessarily reflect the views of USAID or the United States Government.

# រឿង គ្រប់ក្តីស្រលាញ់ ទាំងអស់គឺស្រស់ស្អាត

*All Love is beautiful*



មានលក់អង្ករគ្រប់
ពេលព្រឹកព្រលឹម ម៉ោងប្រហែលជា ៧ ព្រឹក
នៅក្នុងតូបលក់អង្ករក្នុងទីប្រជុំជនមួយ




យុវវ័យម្នាក់ ឈ្មោះ **នរៈ** វ័យខ្ទង់ **២៣**
ចាំបន្តិចមីង ខ្ញុំដាក់ថ្លឹងជូនឥឡូវហើយ
បាន ឬ នៅក្មួយ?


មានលក់អង្ករគ្រប់ប្រភេទ
ជម្រាបសួរ ហ៊ាតុង ថ្ងៃនេះ អញ្ជើញមកប៉ុន្មាននាក់ដែរ ហ៊ា?
ឪពុករបស់នរៈ
ឈ្មោះ ចិន ប៉េង
*ឆ្ងល់*


ទិដ្ឋភាពការញ៉ាំបាយជុំគ្នា នៅក្នុងបន្ទប់ទទួលទានអាហារ
ថ្ងៃនេះ ជាថ្ងៃកម្រណាស់ ដែលគ្រួសារយើងទាំងពីរបានជួបញ៉ាំបាយជុំគ្នាបែបនេះ។ ព្រោះដូចជាខានជួបគ្នាយូរមកហើយ។
ត្រូវហើយ ប៉េងខានជួបគ្នាចូល៥ឆ្នាំហើយ
យុវវ័យម្នាក់នេះ ឈ្មោះ សត្យា វ័យខ្ទង់ ២៣
(ស្ងាត់ មិនមាននិយាយស្ដីតែទឹកមុខឡើងក្រហម)


ចាំតិច
ខ្ញុំប្រកទឹកសិន
នរៈ...តស់! យើងដល់ម៉ោង
គោរពទង់ជាតិហើយ
ត្រលប់ពេលវេលាថយក្រោយ១០ឆ្នាំមុន ពេលដែលនរៈ និងសត្យា
នៅជាសិស្សអនុវិទ្យាល័យនៅឡើយ
មុននេះសត្យានិយាយពាក្យថា
ពួកយើង មែនទេ?
នរៈ ថ្ងៃនេះពួកយើងមានអីញុំា?
បាទ ខ្ញុំនិយាយថាពួកយើង
ហើយមានបញ្ហាអីមែនទេ?
ជារៀងរាល់ព្រឹកនរៈ តែងតែរៀបចំអាហារសម្រន់សម្រាប់ញុំា នៅសាលាពេលម៉ោង
សម្រាក (ចេញលេង) ក្នុងនរៈក៏តែងតែរៀបមួយកញ្ចប់សម្រាប់សត្យាផងដែរ។
យុវវ័យទាំងពីរនាំគ្នាទៅលាងដៃនៅឡាបូលាងដៃ ដែលស្ថិតនៅបរិវេណក្នុងសាលា
ក្រោមដើមឆ័ត្រជំមួយ។ សត្យាចាប់ទាញដៃនរៈមកលាង។ ចំណែកនរៈមានទឹកមុខ
ភ័យបន្តិច ស្រឡាំងកាំងបន្តិច ពេលដែលសកម្មភាពនេះកើតឡើង។
នរៈបែរខ្លួនមកនេះ
ហើយហុចដៃមក

ម៉ោង៩យប់ ទិដ្ឋភាពនៅក្នុងបន្ទប់គេងនៅផ្ទះរៀងៗខ្លួន។ នរៈចាប់ផ្ដើមមានអារម្មណ៍ប្លែកៗចំពោះសកម្មភាពសត្យាពេលថ្មីៗកន្លងមកនេះ។ នរៈសម្លឹងមើលទៅរូបភាពក្នុងទូរស័ព្ទដែលបានថតជាមួយនឹងសត្យា អំឡុងពេលម៉ោងពលកម្មនៅសាលា។




សត្យានឹកស្រមៃពីអនុស្សាវរីយ៍ល្អៗជាមួយនឹងនរៈ ពិសេសពេលដែលនរៈតែងតែរៀបអាហារសម្រន់សម្រាប់ខ្លួនជារៀងរាល់ព្រឹក។


អ្នកគ្រូកំពុងពន្យល់ពីកម្មវិធីចុះស្ម័គ្រចិត្តរបស់សិស្សទៅកាន់តំបន់ដាច់ស្រយាលមួយ ដើម្បីផ្សព្វផ្សាយពីមេរៀន «សិទ្ធិមនុស្ស»
ជម្រាបសួរកូនៗទាំងអស់គ្នាថ្ងៃនេះ អ្នកគ្រូសូមប្រកាសពីរបៀបវារៈពី សកម្មភាព របស់យើង។
ដូចនេះពេលអ្នកគ្រូហៅចំឈ្មោះ សូមងើបថាឡើងដើម្បីឱ្យសមាជិកក្រុមបានស្គាល់គ្នា។
1 សិទ្ធិមនុស្ស
• កម្មវិធីចុះស្ម័គ្រចិត្ត
បាទ/ចាស៎
បាទ/ចាស៎
អ្នកគ្រូបែងចែកសិស្សតាមក្រុមពេលចុះសកម្មភាពស្ម័គ្រចិត្ត។ ងើបឈរម្នាក់ម្ដងៗ
ពិសិដ្ឋ
នរៈ
សត្យា
ពិសី


មុនមួយថ្ងៃដល់ថ្ងៃចុះការងារស្ម័គ្រចិត្តនៅតំបន់ដាច់ស្រយាល នរៈបានកំពុងរៀបចំអីវ៉ាន់ដែលចាំបាច់ប្រើប្រាស់ក្នុងអំឡុងពេលកម្មវិធី។
ក្នុងនោះនរៈនៅតែមិនភ្លេចដាក់កន្សែងពោះគោ ២ឈុត ដែលមួយសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងមួយទៀតសម្រាប់ត្រៀមឱ្យសត្យា
តែកំពុងតែរៀបចំ នរៈក៏ទទួលបានការតេមកនរៈនៅក្នុងក្រុមពីសត្យា...............
រាត្រីសួស្តីណា...
នរៈរបស់ខ្ញុំ
ដូចសព្វមួយដងសត្យាតែងតែមកចូលហៅនរៈ ដើម្បីធ្វើដំណើរទៅជាមួយគ្នា
អើយសត្យា ជួយមើលនរៈផង ព្រោះមីងនេះមិនសូវទុកចិត្តពេលគាត់ចេញដើរឆ្ងាយពីផ្ទះអត់ប៉ាម៉ាក់ទៅជាមួយអីចឹងទេ។
បាទ


ក្រុម ដឹស្ទីកម៉ា (The stigma) ជាឈ្មោះរបស់ក្រុមនរៈ និងសត្យាដែលនឹង
ផ្សព្វផ្សាយពីមេរៀនមួយទាក់ទងនឹងសិទ្ធិរបស់ក្រុមអ្នកស្រលាញ់ភេទដូចគ្នា ។
ជម្រាបសួរអ៊ុំពូមីងទាំងអស់គ្នា ថ្ងៃនេះពួកខ្ញុំជាសិស្សានុសិស្សអនុវិទ្យាល័យ
សូមធ្វើការចែករំលែកនូវប្រធានបទមួយស្តីពី «សិទ្ធិមនុស្សរបស់សហគមន៍អ្នក
ស្រលាញ់ភេទដូចគ្នា» សង្ឃឹមថាអ៊ុំពូមីង បងប្អូន ចូលរួមដោយសកម្ម។
រូបភាពរៀបរាប់ប្រភេទដែលរាប់បញ្ចូលនៅក្នុង
LGBTQI: «ក្រុមអ្នកស្រលាញ់ភេទដូចគ្នា»
L: Lesbian ស្ត្រីស្រលាញ់ស្ត្រី
G: Gay បុរសស្រលាញ់បុរស
B: Bisexual អ្នកស្រលាញ់ពីរភេទ (ទាំងបុរស និងស្ត្រី)
T: Transgender អ្នកផ្លាស់ប្តូរយេនឌ័រ
I: Intersex អន្តរភេទ (បុគ្គលដែលកើតមកមានអវៈយវៈភេទស្រីផងប្រុសផង)
Q: Questioning អ្នកកំពុងស្វែងយល់ពីអត្តសញ្ញាណយេនឌ័រ និងអារម្មណ៍ស្នេហាខ្លួនឯង ឬ
Queer អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង




**នរៈ៖**

បាទប៉ា...សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានេះជាសិទ្ធិមួយនៃសិទ្ធិមនុស្ស ប៉ាដឹងទេបើតាមការស្រាវជ្រាវ និងបទពិសោធន៍ជីវិតរបស់អ្នកស្រលាញ់ភេទដូចគ្នា គឺជាធម្មជាតិ ពីព្រោះរឿងក្តីស្រលាញ់មិនមែនចេះតែធ្វើតាមគ្នាឯណាប៉ាដូចប៉ាអីចឹងមិនមែនប៉ាស្រលាញ់កូនដោយសារ ប៉ាឃើញម៉ែឪគេស្រលាញ់កូនគេឯណាមែនអត់ប៉ា?

ចិនប៉េង៖

បាទ លោកកូន (ចិនប៉េងតបទៅនរៈដោយសំដីឌឺត្រឡប់ទៅវិញ)

**នរៈ៖**

មុននេះខ្ញុំបានប្រាប់ប៉ាខ្ញុំពីសកម្មភាព និងប្រធានបទដែលយើងបានរៀន។

**សត្យាៈ៖**

ហើយឥឡូវយ៉ាងម៉េចហើយ?

**នរៈ៖**

ហ៊ឹម! ខ្ញុំហាក់អន់ចិត្តបន្តិចដែរ

**សត្យាៈ៖**

កុំគិតច្រើនអីវាជារឿងធម្មតាទេ ចាស់ៗគាត់មានផ្នត់គំនិតផ្សេងៗគ្នាទៅតាមសម័យកាល តែគ្នាយល់ថាពេលវេលាប្រាកដជាអាចផ្លាស់ប្តូរផ្នត់គំនិតមួយនេះបានជឿគ្នាទៅ។

**នរៈ៖**

ពេលណាទៅ?

**សត្យាៈ៖**

ពេលដែលខ្ញុំទៅជម្រាបសួរប៉ាម៉ាក់នរៈជាផ្លូវការដល់ផ្ទះទេដឹង...




ទិដ្ឋភាពនៅតាមសួនច្បារ នៃកណ្ដាលទីរួមស្រុក
សត្យា៖
តស់! នរៈ ដល់ម៉ោងហើយ
នរៈ៖
ចាំបន្តិច
សត្យា៖
កុំធ្វើខ្លួនយូរពេក ប៉ុណ្ណឹង ស្អាតហើយ
នរៈចាប់ផ្ដើមងរនឹងសត្យា
សត្យាបានទៅយកនរៈ ដើម្បីទៅដើរ ហាត់ប្រាណ និងលេងវាយសីជាមួយគ្នា
អូយ!
ឡើងហើមបាត់ ទៅហើយ
ម៉េចហើយ?
ឃើញអត់ ពេល រត់អត់ប្រយ័ត្ន អីចឹងហើយឈប់ លេងត្រឹមនេះ ហើយចាំខ្ញុំឌុប ទៅផ្ទះវិញ
តាមផ្លូវត្រលប់មកពីលេងសីសត្យាជាអ្នកជិះកង់ឌុបនរៈទៅផ្ទះវិញ
នរៈដៃ You នៅណា?
ហើយរកធ្វើអី?
ហុចដៃមកកាន់ចង្កេះ Me មក ខ្លាចជិះរលាក់ៗ ជ្រុះនរៈបាត់តាមផ្លូវ
នរៈមុខឡើងក្រហមស្របពេលដែលសត្យាទាញដៃខ្លួនទៅអោបចង្កេះគេ

សត្យា និងនរៈបានឈប់សម្រាកនៅក្បែរមាត់បឹងក្រោមដើមឈើធំមួយ។ ពេលនោះដែរ នរៈ និងសត្យាបានបង្ហាញពីអារម្មណ៍របស់ពួកគេទៅវិញទៅមក។







(ទាំងពីរនាក់ញញឹមមើលមុខគ្នា ដោយកែវភ្នែកស្រទន់)

សត្យាបានព្យាយាមទៅលេងផ្ទះនរៈកាន់តែញឹកញាប់ និងបង្ហាញការយកទុកចិត្តរបស់ខ្លួនទៅលើនរៈដើម្បីឱ្យចិនប៉េងបានដឹងខ្លះៗថាគេកំពុងតែទាក់ទងគ្នាព្រោះបើប្រាប់ត្រង់អ្នកទាំងពីរដឹងថាមិនអាចជំនះលើគ្រួសារបានទេ ព្រោះហេតុផលម្យ៉ាងខ្លួនកំពុងតែរៀនមួយវិញទៀត រឿងនេះត្រូវការពេលបន្ថែមដើម្បីអាចឱ្យពួកគាត់យល់ និងទទួលយក។



ពេលជួបនរៈ សត្យាបានយករឿងដែលតេស្តចិត្តម្តាយនរៈទៅនរៈ




ពេលនេះ វាមិនមែនជាពេលវេលាសមស្របទេ។
ចាតើពេលណាយើងអាចបង្ហាញវាជាសាធារណៈបាន?
ជឿទេថាពេលវេលាអាចផ្លាស់ប្តូរការគិតរបស់មនុស្ស?
មិនបាន១០០%ទេ មនុស្សអាចផ្លាស់ប្តូរការគិត តែបើសិនពួកគាត់បើកចិត្តទទួលស្តាប់នូវហេតុផល
ទិដ្ឋភាពក្រោមដើមឈើធំមួយក្បែរមាត់បឹងសត្យា និងនរៈបានកំពុងពិភាក្សាគ្នាពីរឿងរ៉ាវរបស់គេទាំងទឹកមុខសោកសៅ ព្រោះពួកគេទាំងពីរមានគំនាបពីគ្រួសារមិនអាចបើកបង្ហាញនូវអត្តសញ្ញាណយេនឌ័ររបស់ខ្លួនឯងបានគេបានធ្វើការពិភាក្សាគ្នាអំពីបញ្ហានេះ
បន្តពីការពិភាក្សានរៈ និងសត្យាបានមើលមុខគ្នាដោយក្តីស្រលាញ់ ប៉ុន្តែកែវភ្នែកបង្ហាញពីការលាក់បាំងភាពសោកសៅ។




នរៈ និងសត្យាបានឈរកាន់ដៃគ្នា មើលលទ្ធផលនៃការប្រលងបាក់ឌុបនៅលើផ្ទាំងក្តារខៀន ដែលបិទនៅមុខទីចាត់ការ




នរៈ និងសត្យាធ្វើការពិភាក្សាគ្នាទាក់ទងនឹងការរៀនបន្តទៅសាកលវិទ្យាល័យ ប៉ុន្តែអ្នកទាំងពីរសុទ្ធតែមានក្តីស្រមៃរៀងៗខ្លួន ជាហេតុធ្វើឱ្យការពិភាក្សាមួយនេះក្លាយជាការពិភាក្សាមួយដែលមិនសូវមានភាពរីករាយ។




ខ្ញុំមានក្ដីស្រមៃបន្តមុខរបររបស់គ្រួសារ ហើយខ្ញុំគ្រាន់តែចង់បានជីវិតមួយដែលស្ងប់ស្ងាត់ និងសាមញ្ញប៉ុណ្ណោះ
សត្យា៖
ចុះខ្ញុំ? នរ:ចង់ទុកខ្ញុំចោលមែនទេ?


នរ:៖
ពាក្យមួយណាដែលខ្ញុំនិយាយថាទុកសត្យាចោល? សត្យានៅតែជាមនុស្សសំខាន់សម្រាប់ខ្ញុំ ហើយខ្ញុំក៏ចង់ឱ្យសត្យាគោរពការសម្រេចចិត្តរបស់ខ្ញុំដែរ។
ប៉ុន្តែវានឹងធ្វើឱ្យពួកយើងរស់នៅបែកគ្នាណា




(នរៈយកដៃចាប់មួលភ្លៅសត្យាហើយភ្នែកសម្លក់ថ្លៃរដោយទឹកមុខឡើងក្រហម
និងពោលថា)




*ស្នេហ៍ឆ្ងាយកាយ អំឡុងពេលដែល សត្យា រៀនសាកលវិទ្យាល័យ នៅទីក្រុង ពួកគេអស់ នៅតែមានទំនាក់ទំនង ជាមួយគ្នាដដែល
សកលវិទ្យាល័យភូមិន្ទ
ដោយពួកគេទាក់ទង តាមរយៈប្រព័ន្ធអនឡាញ គ្រាន់តែមិនបានជួបមុខ គ្នាផ្ទាល់ ប៉ុន្តែមានពេល មួយដែលចិនប៉េងទទួល បានទូរស័ព្ទពីសំណាក់ គ្រួសារហ៊ាតុង ថាមក ហូបបាយនៅផ្ទះចិនប៉េង ទើបពួកគេទាំងពីរបាន ជួបគ្នាវិញម្តងទៀត។
មកដល់បច្ចុប្បន្នភាពវិញ បន្ទាប់ពីថ្ងៃដែល គ្រួសារទាំងពីរហូបបាយជុំគ្នា
ក្រោយការណាត់អាហារបានមួយសប្តាហ៍នរៈ និងសត្យាបានបង្ហាញទំនាក់ទំនងរបស់ ខ្លួនជាសាធារណៈ តែត្រូវបានកូនស្រីរបស់អ្នកជិតខាងចិនប៉េងយកទៅប្រាប់គាត់។


នរៈ ប៉ាចង់និយាយជាមួយកូន។
ចិនប៉េងគ្រាន់តែបានដឹងរឿងនេះគាត់ខឹងជាខ្លាំង និងបានប្រើពាក្យសម្តីធ្ងន់ៗ លើកូនខ្លួន និងសត្យា


នរៈ ប៉ាឮថាកូនទាក់ទងស្នេហា ជាមួយសត្យា។ តើរឿងនេះវា កើតឡើងតាំងពីពេលណា?
បាទ ប៉ាតាំងពីពួកខ្ញុំនៅរៀន ជាមួយគ្នាមកម្ល៉េះ។
ថាហើយថាទៀតស្អប់អីវាទៅហ្នឹង បើនៅភ្លើអីចឹងទៀតកុំហៅយើងថាឪ។ រឿងមានប្រយោជន៍មិនខំទេ ខំអារឿងភ្លើជោរតាមគ្នាហ្នឹង។




**សត្យា៖**

ការស្រលាញ់មិនអាចកំណត់បានទេប៉ា ហើយខ្ញុំដឹងពីទំនោរនៃក្តីស្រលាញ់របស់ខ្ញុំថាខ្ញុំស្រលាញ់បែបណា ដូចនេះខ្ញុំសុំចិត្តប៉ា និងអ្នកផ្ទះកុំរារាំងខ្ញុំអី ត្បិតអីប៉ាតែងតែលើកឡើងថាអ្នកផ្ទះជាកម្លាំងជំរុញទឹកចិត្តឱ្យខំរកស៊ីបន្ត ចុះឥឡូវខ្ញុំមានអ្នកណាជំរុញចិត្តបន្តទៅមុខទៀត បើអ្នកផ្ទះក៏មិនគាំទ្រទៅហើយ?


នរៈ ចាប់ផ្ដើមលែងចង់ញ៉ាំបាយញ៉ាំទឹក ព្រោះពិបាកចិត្តរឿងគ្រួសាររបស់ខ្លួន និងរឿង
ចិនប៉េង ពេលនោះម្ដាយនរៈបានលួចមើលកូន និងសម្រក់ទឹកភ្នែក


ម្ដាយនរៈបានទៅនិយាយជាមួយប្ដីគាត់
មើលម៉ែវា ខ្ញុំធ្វើនេះវាត្រឹមត្រូវឬខុស? គ្រាន់តែចង់ឱ្យកូនល្អ និងមានអនាគតដូចគ្នាកុំឱ្យជោរតាមគ្នាហេតុអ្វីក៏កូនមិនយល់ពីខ្ញុំ?
ចាប៊ីតែតឹងពេក ប្រយ័ត្នតែវាដាច់ណាប៉ាវា (និយាយចប់ម្ដាយនរៈជូតទឹកភ្នែក)

កន្លងទៅមួយសប្ដាហ៍ ក្រោយពីគ្រួសារទាំងពីរបានដឹងរឿងទំនាក់ទំនងរបស់នរៈ និងសត្យា។ ហ៊ាតុង និងចិនប៉េងបានទូរស័ព្ទជួបគ្នា ហើយពិភាក្សាគ្នាព្រោះត្បិតថា ចាប់តាំងពីថ្ងៃនោះមកទាំងនរៈ និងសត្យាលែងចង់ចេញពីបន្ទប់លែងចង់និយាយស្ដីរកអ្នកផ្ទះ។




**ចិន ប៉េង៖**

តុងមកជួយគិតគ្នាមើល តើធ្វើយ៉ាងម៉េចជាមួយនឹងរឿងកូនៗហ្នឹង?

**ហ៊ា តុង៖**

ខ្ញុំនឹងឱ្យសត្យាទៅរៀនបន្ថែមទៀត ដើម្បីឱ្យគេផ្ដាច់ទំនាក់ទំនងគ្នា

**ចិន ប៉េង៖**

ហ៊ឹម...វិធីនេះក៏ល្អម្យ៉ាងដែរ មានតែសាកសិនហើយ។

និយាយទូរសព្ទ័ជាមួយគ្នារួច ពួកគាត់ក៏ទៅពិភាក្សាជាមួយកូនរៀងៗខ្លួន






**ហ៊ា តុង៖**

ចុះអារឿង ឯងទៅស្រលាញ់កូនចិនប៉េងនោះវាយ៉ាងម៉េច? ប្រុសស្រលាញ់ប្រុសដូចគ្នាឯងគិតថារឿងហ្នឹងគ្រួសារមិនខ្មាសគេទេ? វាល្អមុខណាស់ទៅ? សត្យាឯងធ្វើអីចឹងមានអាណិតប្អូនទេ? ថាប្អូនខ្មាស់គេប៉ុណ្ណាដែលមានបងប្រុសហ្នឹងគេ តែមិនសមជាប្រុស?

**សត្យា៖**

ប៉ាដឹងអត់ អ្នកផ្សេងគេរើសអើងពួកខ្ញុំដោយសារអី? ដោយសារសូម្បីតែអ្នកផ្ទះជាមួយគ្នាផងក៏មិនគាំទ្រគ្នា ហើយជាន់ពួកខ្ញុំពន្លិចថែមនេះឯង។

**ហ៊ា តុង៖**

កុំមកដំឡើងសំលេងណាសត្យា ប៉ាចិញ្ចឹមឯងមកមិនមែនឱ្យឯងធ្វើអីចឹងទេ។

**សត្យា៖**

(ដំឡើងសំលេង) ប៉ាដូចជាហួសហេតុខ្លាំងហើយ


សត្យាបានរៀបចំសម្ភារៈយ៉ាងច្រើន ក្នុងគោលបំណងរើចេញពីផ្ទះហើយ លែងត្រប់មកទៀត ព្រោះថាគ្មាន នរណាម្នាក់ដែលជាសមាជិកគ្រួសារ យល់ពីគាត់ទៀតឡើយ ពេលកំពុង រៀបចំខោអាវសត្យាបានផ្ញើសារទៅនរៈ ហើយប្រាប់ពីផែនការរបស់ខ្លួន និង បបួលនរៈទៅរស់នៅជាមួយគ្នា
សត្យា៖ បងសម្រេចចិត្តហើយ ថានឹងរើចេញ
នរៈ៖ ចង់ទៅណាបង?
សត្យា៖ ទៅណាក៏បានឱ្យ តែបានចេញផុតពីផ្ទះនេះ
នរៈ៖ ចុះខ្ញុំ? បងចង់ទុកខ្ញុំចោល?
សត្យា៖ នរៈរៀបចំអីវ៉ាន់ឱ្យហើយទៅ យប់ម៉ោង១១បងទៅយក។




ម្ដាយនរៈលួចឃើញ និងស្ដាប់ឮការសន្ទនារបស់នរៈ
និងសត្យាហើយបានរត់ទៅឃាត់កូន


កុំធ្វើអីចឹងអី អាណិតចិត្តម៉ាក់ផង
នរៈ៖
ខ្ញុំមិនចង់អីចឹងទេម៉ាក់ តែផ្ទះនេះលែងជាកន្លែងកក់ក្ដៅតែមួយសម្រាប់ខ្ញុំទៀតហើយ
អាណិតម៉ាក់ណាកូនណា... ចាំម៉ាក់ទៅនិយាយជាមួយប៉ាកូនម្ដងទៀតណា
នរៈយំឱបម្ដាយ


ប៉ាវា ខ្ញុំមិនមែននិយាយដដែលៗទេ តែធ្វើ
អីចឹងប្រយ័ត្នកូនលែងមកជួបមុខរហូត
ហើយឱ្យខ្ញុំធ្វើយ៉ាងម៉េច? ឯង
គិតថាវាល្អមុខគ្រួសារយើង
ណាស់ទៅ? តែ...
គិតមើលកូនយើងមិនមែនជាចោរលួចឆក់គេឯណាគ្នាគ្រាន់តែធ្វើអីដែលគ្នាស្រលាញ់
ធ្វើម៉េចបើរឿងវាបានជាបែបនេះហើយ ហេតុអីយើងមិនលើកទឹកចិត្តកូនយើង? គ្រាន់
កូនគិតអីផ្តេសផ្តាស់។ និយាយតាមត្រង់ទៅខ្ញុំបារម្ភពីកូនណាស់ពីមួយថ្ងៃទៅមួយថ្ងៃ
សភាពរបស់កូនយើងដូចជាមិនមានអ្វីល្អប្រសើរ ទោះបីយើងនិយាយ និងហាមបែប
ណាក៏មិនបានអ្វីល្អប្រសើរដែរ ហើយថែមទាំងធ្វើឱ្យកូនកាន់តែរឹងរូស
ខ្ញុំពិតជាខ្លាច ...ខ្លាចបាត់បង់កូន។
តែវាអី ប៉ាវា?
ហ៊ាតុង...


ចំណតឡានក្រុង


ចិនប៉េង និយាយជាមួយហ៊ាតុង៖
បើចាប៉ីតឹងវាដាច់ ហ៊ាសុខចិត្ត
តាមកូនហើយខំរាល់ថ្ងៃក៏ដើម្បី
តែកូន ហើយណា មួយវាទាំង
ពីនេះក៏មិនប្រព្រឹត្តិបទល្មើស
អីដែរ តាមវាសនាវាទាំងពីរចុះ។


សត្យា៖
នរៈឱ្យខ្ញុំសុំទោសដែលមិនបាននៅក្បែរនរៈ ពេលមានបញ្ហាបែបនេះ
នរៈ៖
សុំទោសអី ខ្ញុំដឹងសត្យាក៏ជួបបញ្ហាអំឡុងខ្ញុំជាប់ក្នុងបន្ទប់។ ចុះគ្រួសារសត្យាយ៉ាងណាហើយគាត់មានស្តីឱ្យសត្យាទៀតទេ?
សត្យា៖
ក្រោយពីរឿងនរៈបានកើតឡើងចិនប៉េងបាននិយាយទូរស័ព្ទជាមួយប៉ាខ្ញុំ ចាប់តាំងពីពេលនោះមកគាត់មិនទំនាស់អ្វីទៀតទេ
នរៈ៖
អីចឹងបានន័យថា រឿងយើងពីរនាក់ក្រោយភ្លៀងមេឃស្រលះមែន?
សត្យា៖
រួចមានភ្លៀងមានផ្គរតាំងពីកាលហ្នឹង?
ចប់

## សារពីអ្នកនិពន្ធ៖

ការស្រលាញ់ គឺមានភាពស្រស់ស្អាតណាស់។ គ្រប់គ្នាតែងតែមានភ្ជាប់នូវទំនោរការស្រលាញ់តាំងពីកំណើតរបស់ខ្លួនមកម្ល៉េះ គ្រាន់តែមានអ្នកខ្លះបានជំនះរនាំងផ្នត់គំនិតសង្គម រនាំងនូវការខកខាននៃការទទួលស្គាល់ផ្នែកក្របខ័ណ្ឌច្បាប់រួចហើយ ដើម្បីអាចរស់នៅជាមួយដៃគូ ដែលខ្លួនពួកគេពេញចិត្ត ហើយអ្នកខ្លះទៀតកំពុងតែព្យាយាមជំនះឧបសគ្គទាំងនេះ។ ទោះបីជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មិនបានបញ្ជាក់ជាក់លាក់ទាក់ទងនឹងបុគ្គលស្រលាញ់ភេទដូចគ្នាក្តី តែក្រោមមាត្រា៣១នៃច្បាប់រដ្ឋធម្មនុញ្ញនូវតែជានាសិទ្ធិស្មើភាពគ្នា ចំពោះប្រជាពលរដ្ឋកម្ពុជាទាំងអស់ផងដែរ។ អ្នកស្រលាញ់ភេទដូចគ្នាក៏ជាក្រុមមនុស្សដែលរស់នៅលើភពផែនដីនេះ ហើយវាចាំបាច់ណាស់ដែលពួកគាត់ត្រូវតែទទួលបានការគោរពសិទ្ធិ និងសេរីភាពផ្សេងៗដូចដែលមានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ទាំងឡាយណាដែលស្របនឹងសិទ្ធិមនុស្ស។ ទាំងអស់គ្នាមានសិទ្ធិ មានសេរីភាពស្មើៗគ្នាក្នុងការជ្រើសរើសក្នុងនាមជាមនុស្សជាតិ។



ISBN: 978-9924-9966-4-4